ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# កម្មវិធីបណ្តុះបណ្តាល

## ស្តីពី

## ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប

សម្រាប់ខេត្តសៀមរាប

ថ្ងៃទី២៧-២៨ ខែកញ្ញា ឆ្នាំ២០២១

រៀបចំដោយ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

# ការកំណត់អត្តសញ្ញាណ

## មេរៀនទី១៖ សារសំខាន់ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណ

ឯកសារបង្អែក៖ សៀវភៅគោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ
ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប


រៀបរៀងដោយ ក្រុមការងារបណ្តុះបណ្តាល នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

ដឹកនាំដោយលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

បង្ហាញដោយ៖ លោកស្រីវេជ្ជ. **ថោង សុវត្តី**

អនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ

# គោលបំណងនៃមេរៀន

ដើម្បីឲ្យសិក្ខាកាមបានយល់ដឹងពី៖

- សារសំខាន់ នៃការកំណត់អត្តសញ្ញាណ និងពត៌មានពិត ដែលទទួលបានពីជនរងគ្រោះ ដែលជាមូលដ្ឋានគ្រឹះ នៃការរៀបចំច្បាប់ គោលនយោបាយ ផែនការ និងវិធានការនានា ឆ្លើយតបទៅនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងផ្តល់យុត្តិធម៌ និងសេវាកម្មដល់ជនរងគ្រោះពិតប្រាកដ ជៀសវាងការវិលទៅរកភាពរងគ្រោះជាថ្មី
- អ្នកដែលមានភារកិច្ច និងតួនាទីកំណត់អត្តសញ្ញាណ
- នីតិវិធី ជាដំណាក់កាល ដើម្បីសម្ភាសន៍ ប្រមូលពត៌មានពីជនសង្ស័យថារងគ្រោះ

# សារសំខាន់ នៃការកំណត់អត្តសញ្ញាណជនរងគ្រោះ



# សារសំខាន់ នៃការកំណត់អត្តសញ្ញាណជនរងគ្រោះ

## ហេតុអ្វីបានជាយើងត្រូវកំណត់

## អត្តសញ្ញាណជនរងគ្រោះ ?

# សារសំខាន់ នៃការកំណត់អត្តសញ្ញាណជនរងគ្រោះ (ត)

- សន្និដ្ឋានជនរងគ្រោះ ពិតប្រាកដ
- ដឹងអំពីស្ថានភាព សេចក្តីត្រូវការ សំណូមពរ ដើម្បីឆ្លើយតបឲ្យបានសមស្រប៖
    - តម្រូវការផ្នែកសន្តិសុខ សុវត្ថិភាព
    - ការព្យាបាលសុខភាពផ្លូវកាយ ផ្លូវចិត្ត
    - ជម្រកសុវត្ថិភាពបណ្តោះអាសន្ន
    - ការស្តារនីតិសម្បទា
    - កិច្ចការពារផ្លូវច្បាប់
    - សុខុដុមនីយកម្មនៃការធ្វើសមាហរណកម្ម ...
- រៀបចំគោលនយោបាយ ផែនការ កម្មវិធី ឆ្លើយតបបានត្រឹមត្រូវ សម្រាប់ការបង្ការទប់ស្កាត់ ការផ្តល់កិច្ចការពារ និងគាំពារជនរងគ្រោះ ការស្វែងរកជនល្មើស ដើម្បីផ្តន្ទាទោសឲ្យបានត្រឹមត្រូវតាមច្បាប់ និងមានវិធានការក្នុងការបង្ក្រាប និងកាត់បន្ថយប្រសិទ្ធភាព នៃបទល្មើស បានឡើយ ។
- អាចរកឃើញបទល្មើសផ្សេង ឬ ភាពរងគ្រោះផ្សេងទៀត ដែលត្រូវសង្គ្រោះ

# សារសំខាន់ នៃការកំណត់អត្តសញ្ញាណជនរងគ្រោះ (ត)

- ការកំណត់អត្តសញ្ញាណ **មិនបានត្រឹមត្រូវ៖**

➡ ជនរងគ្រោះ
  - កាន់តែឈឺចាប់
  - កាន់តែបាក់ស្បាត
  - កាន់តែភ័យខ្លាច
  - មិនបានទទួលពីភាពប្រសើរឡើងក្នុងជីវិត

ជនល្មើស
  - កាន់តែមានឱកាស
  - មានឥទ្ធិពល
  - មានលទ្ធភាព  ក្នុងការបង្កើត និងពង្រីកបទល្មើស បង្កភាពរងគ្រោះដល់សង្គមកាន់តែច្រើន

សង្គមជាតិ
  - បន្តការខាតបង់កាន់តែធ្ងន់ធ្ងរ
  - ប៉ះពាល់ដល់ធនធានអភិវឌ្ឍន៍គ្រប់វិស័យ
  - ខូចខាតកិត្តិយស យ៉ាងធ្ងន់ធ្ងរ លើឆាកអន្តរជាតិ

# នីតិវិធីនៃការសម្អាតសន់
# ដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស

# ១. អ្នកមានសមត្ថកិច្ចកំណត់ អត្តសញ្ញាណ

**អាជ្ញាធរមូលដ្ឋាន**
ឃុំ/សង្កាត់ ស្រុក/ក្រុង/ខណ្ឌ ខេត្ត/
រាជធានី

**នគរបាលយុត្តិធម៌**

**មន្ត្រីនិងអ្នកពាក់ព័ន្ធ**
ក្រោមយន្តការនៃការប្រយុទ្ធប្រឆាំងនឹងអំពើ
ជួញដូរមនុស្សក្នុងរចនាសម្ព័ន្ធទាំងនៅថ្នាក់ជាតិ
និងថ្នាក់ក្រោមជាតិ

**មន្ត្រីស្ថានទូត / ស្ថានតំណាង**
នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅ
ប្រទេសគោលដៅ



**ដែលបានទទួលវគ្គបណ្តុះបណ្តាលរួច**

**អង្គការសង្គមស៊ីវិល**
ដែលធ្វើការងារពាក់ព័ន្ធនឹងការជួយ
ជនរងគ្រោះ

**មន្ត្រីសង្គមកិច្ច**

**មន្ត្រីកិច្ចការនារី**

**មន្ត្រីទទួលបន្ទុក**
កិច្ចការនារីនិងកុមារ

# ២.ដំណាក់កាលសំខាន់ៗនៃការកំណត់អត្តសញ្ញាណ

ដំណាក់កាលទី១

**ការជួបដំបូង**

ដំណាក់កាលទី២

**ការត្រៀមសម្ភាសន៍**

ដំណាក់កាលទី៣

**ការសម្ភាសន៍ជាផ្លូវការ**

# ២. ដំណាក់កាលសំខាន់ៗនៃការកំណត់អត្តសញ្ញាណ (ត)

## ដំណាក់កាលទី១៖ ការជួបដំបូង

### សង្កេតបឋម៖

ពិនិត្យមើល ឥរិយាបថ អាកប្បកិរិយា របៀបប្រាស្រ័យទាក់ទង ទឹកមុខ អារម្មណ៍ ។ល។ ដែលគួរឲ្យសង្ស័យថាជាអនីតិជន និង កម្រិតនៃភាពរងគ្រោះ





### ការប្រាស្រ័យទាក់ទង៖

ធ្វើការទំនាក់ទំនងបឋម ដើម្បីស្វាបស្ទង់ និងប៉ាន់ប្រមាណអំពីតម្រូវការ និងឧបសគ្គ ក្នុងការសម្ភាសន៍

### ឧបសគ្គ៖

ភាសា វប្បធម៌ យេនឌ័រ វ័យ ។ល។ ដែលខុសៗគ្នា គឺជាឧបសគ្គ ដែលចាំបាច់ត្រូវសម្របសម្រួលអារម្មណ៍ ឬរកអ្នកសម្ភាសន៍ដែលសមស្រប ឬរកអ្នកបកប្រែ





### សង្កេត៖

រកវត្ថុតាងឬភស្តុតាងផ្សេងៗ ដែលអាចបញ្ជាក់អំពីភាពរងគ្រោះ (សម្ភារជាប់ខ្លួន ទឹកមុខ ស្នាមរបួស ឬកាយវិការ...)

# ២. ដំណាក់កាលសំខាន់ៗនៃការកំណត់អត្តសញ្ញាណ (ត)

## ដំណាក់កាលទី១៖ ការជួបដំបូង (ត)

* ចំណាំ៖

- ត្រូវដាក់ការសង្ស័យថាជាជនរងគ្រោះដើម្បីឈានទៅដល់ការកំណត់អត្តសញ្ញាណ
- ក្នុងករណីដែលចំនួនអ្នកសម្ភាសតិចជាងជនរងគ្រោះ ត្រូវកំណត់ថាគួរសម្ភាសន៍អ្នកណាមុន ឬសម្ភាសន៍ជាក្រុម
- ត្រូវប្រុងប្រយ័ត្នក្នុងករណីដែលក្នុងក្រុម មានអ្នកសង្ស័យថាជាមេខ្យល់ ឬជាជនដែលអាចពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស ឬជាមួយជនល្មើស

# ២. ដំណាក់កាលសំខាន់ៗនៃការកំណត់អត្តសញ្ញាណ (ត)

**ដំណាក់កាលទី២៖ ការត្រៀមសម្ភាសន៍**

**អ្នកសម្ភាសន៍៖**

- ត្រៀមអ្នកសម្ភាសន៍ដែលមានបច្ចេកទេសក្នុងការសម្ភាសន៍ប្រកបដោយក្រមសីលធម៌
- រកអ្នកសម្ភាសន៍ដែលមានភេទដូចគ្នានឹងជនសង្ស័យរងគ្រោះ (បើអាចរកបាន) ឬអ្នកដែលមានបទពិសោធន៍ (ការងារយេនឌ័រ ឬកិច្ចការកុមារ)

**សម្ភារបម្រើឲ្យការសម្ភាសន៍ ៖**

- ទម្រង់សម្រាប់ការសម្ភាសន៍
- ទម្រង់ស្នើសុំការយល់ព្រមពីអ្នកដែលត្រូវសម្ភាសន៍ (សម្រាប់ការសម្ភាសន៍លម្អិត)
- សម្ភារចាំបាច់៖ ប៊ិច/ខ្មៅដៃ សៀវភៅ/ក្រដាស ...
- ឧបករណ៍ថតសំឡេង កាមេរ៉ាថតរូប/វីដេអូ (បើមាន)
- ឧបករណ៍សម្រាប់ការសម្ភាសន៍បែបកុមារមេត្រី

# ២. ដំណាក់កាលសំខាន់ៗនៃការកំណត់អត្តសញ្ញាណ (ត)

## ដំណាក់កាលទី២៖ ការត្រៀមសម្ភាសន៍ (ត)

**ទីតាំងសម្ភាសន៍៖**

- សមរម្យ
  - ទីកន្លែង ឬបន្ទប់មិនមានសម្លេងរំខាន
  - ទីកន្លែងមានពន្លឺគ្រប់គ្រាន់
  - ទីកន្លែងមានខ្យល់អាកាសគ្រប់គ្រាន់
- មានសុវត្ថិភាព
- មិនប៉ះទង្គិចអារម្មណ៍

**ភាសាទំនាក់ទំនង៖**

- រកអ្នកបកប្រែ (បើចាំបាច់)
- ប្រើភាសាប្រកបដោយសុជីវធម៌

# ២. ដំណាក់កាលសំខាន់ៗនៃការកំណត់អត្តសញ្ញាណ (ត)

**ដំណាក់កាលទី៣៖ ការសម្ភាសន៍ជាផ្លូវការ**

សម្គាល់: ជនរងគ្រោះ ភាគច្រើនមានភាពរារែក ក្នុងការផ្តល់ព័ត៌មាន



- ដោយសារតែការខ្មាស់អៀន
- អាចចាំមិនបាន
- អាចរងនូវការគំរាមកំហែង
- លួងលោមពីមេខ្យល់ ឬថៅកែ ឬជនណាម្នាក់ ឬសាច់ញាតិ
- ភ័យខ្លាចក្រែងមានការចាប់ទោសកំហុស ធ្វើឲ្យខ្លួនធ្លាក់ទៅក្នុងស្ថានភាពកាន់តែលំបាក
- ខ្លួនមានជាប់ពាក់ព័ន្ធនឹងអំពើខុសច្បាប់មួយចំនួនមុនពេល ក្នុងអំឡុងពេលដែលខ្លួនស្ថិតនៅក្នុងស្ថានភាពរងគ្រោះជាដើម ។

# ២. ដំណាក់កាលសំខាន់ៗនៃការកំណត់អត្តសញ្ញាណ (ត)

**ដំណាក់កាលទី៣៖ ការសម្ភាសន៍ជាផ្លូវការ** (ត)



- អ្នកសម្ភាសន៍ត្រូវព្យាយាមសង្កេតទឹកមុខកាយវិការ ក្រសែភ្នែក របស់អ្នកឆ្លើយ ដែលបញ្ជាក់ពី៖ អារម្មណ៍ ភ័យខ្លាច ឬលាក់លៀម ឬជាចម្លើយពិត ឬមិនពិត ។ ក្នុងស្ថានភាពនេះ អ្នកសម្ភាសន៍ត្រូវមានវិធីសាស្រ្តក្នុងការផ្អាកការសាកសួរ សម្រួលអារម្មណ៍ ឬប្តូរ សំណួរដើម្បីឲ្យអ្នកឆ្លើយមានឱកាសក្នុងការផ្តល់ចម្លើយ។

- ក្នុងករណីអ្នកផ្តល់បទសម្ភាសន៍ជាកុមារ ត្រូវប្រើវិធីសាស្រ្តបែបកុមារមេត្រី ដោយមានការលួងលោម ផ្តល់សម្ភារជាល្បែងក្មេងឬនំចំណីដើម្បីឲ្យក្មេងមានអារម្មណ៍ល្អ និងឆ្លើយតប។

# ២. ដំណាក់កាលសំខាន់ៗនៃការកំណត់អត្តសញ្ញាណ (ត)

## ដំណាក់កាលទី៣៖ ការសម្ភាសន៍ជាផ្លូវការ (ត)

### ដើម្បីទទួលបានព័ត៌មានពីជនដែលត្រូវធ្វើសម្ភាសន៍៖

- អ្នកសម្ភាសន៍គប្បីអនុវត្តតាមវិធីសាស្ត្រ និងក្រមសីលធម៌ នៃអ្នកសម្ភាស (ឧបសម្ព័ន្ធ១ ទំព័រ ៣០-៣៦)
- រក្សាការសម្ងាត់
- ផ្តល់ព័ត៌មានពេញលេញ និងការស្នើសុំការយល់ព្រម (ទម្រង់ស្នើសុំការយល់ព្រម ដែលមានស្នាមខ្មៅដៃ ជនដែលត្រូវសម្ភាស)
- ធានាសុវត្ថិភាព សន្តិសុខ និងផាសុកភាព
- ធានាឯកជនភាព
- សួរសំណួរដែលមានលក្ខណៈសាមញ្ញ និងប្រកបដោយវិជ្ជាជីវៈ
- ស្តាប់ប្រកបដោយលក្ខណៈសកម្ម និងឆ្លើយតប

# ២. ដំណាក់កាលសំខាន់ៗនៃការកំណត់អត្តសញ្ញាណ (ត)

## ដំណាក់កាលទី៣៖ ការសម្ភាសន៍ជាផ្លូវការ (ត)

- ព្យាយាមលើកទឹកចិត្តអ្នកឆ្លើយ មិនបង្កការប៉ះទង្គិចផ្លូវកាយ ផ្លូវចិត្ត ការរើសអើងក្នុងសង្គម
- ធានាឲ្យមានអារម្មណ៍ និងឥរិយាបថមិនលម្អៀង
- ឥរិយាបថប្រកបដោយមនុស្សធម៌ ការយល់ចិត្ត ការគោរព និងសមភាព
- សម្រួលឲ្យអ្នកឆ្លើយមានម្ចាស់ការលើខ្លួនឯង លើកទឹកចិត្តមិនបន្ទោសខ្លួនឯង
- ពន្យល់ប្រាប់អំពីសិទ្ធិក្នុងការសុំធ្វើកោសល្យវិច័យ និងការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ

# ២. ដំណាក់កាលសំខាន់ៗនៃការកំណត់អត្តសញ្ញាណ (ត)

## ដំណាក់កាលទី៣៖ ការសម្ភាសន៍ជាផ្លូវការ (ត)

- ការបកប្រែភាសា (តាមការចាំបាច់)
- ផ្អាកការសម្ភាសន៍ក្នុងករណីចាំបាច់ (ប៉ះពាល់អារម្មណ៍ជនរងគ្រោះធ្ងន់ធ្ងរ ឬ មានបញ្ហាសុខភាព ឬមានការរំខានផ្សេងៗ)
- ត្រៀមការបញ្ជូនជនរងគ្រោះតាមនីតិវិធី ទៅគោលដៅផ្សេងទៀត (តាមការចាំបាច់)
- ជៀសវាងធ្វើឲ្យអ្នកឆ្លើយរំពឹងទុកខុសពីការពិត

ការប្រមូលព័ត៌មានឲ្យបានគ្រប់ជ្រុងជ្រោយ ឈានទៅដល់ការសន្និដ្ឋានថាជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឬមិនមែន ។

# សំនួរ - ចម្លើយ - ការពិភាក្សា




សូមអរគុណ!